ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៤០ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសាធារណការ និងដឹកជញ្ជូន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៧/០០៧ ចុះថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសអោយប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ ១៤ អនក្រ.បក ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

### ជំពូកទី ១

### បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះ មានគោលដៅបង្កើតគណៈកម្មាធិការ ដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ បើកបរលើបណ្តាញផ្លូវនៅទូទាំងព្រះរាជាណាចក្រកម្ពុជាដែលគ្រប់គ្រងដោយក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ២ .-**

អនុក្រឹត្យនេះមានគោលបំណង ÷

- ដាក់ចេញនូវវិធានការទប់ស្កាត់រាល់ការដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- គ្រប់គ្រងស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ស្ថិតនៅតាមបណ្តាញផ្លូវ ដែលគ្រប់គ្រងដោយក្រសួងសាធារណការ និងដឹកជញ្ជូន
- ទប់ស្កាត់ការបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ដោយសកម្មភាពដឹកជញ្ជូនលើសទម្ងន់ ដើម្បីការពារហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ឱ្យបានស្ថិតស្ថេរយូរអង្វែងស្របតាមបច្ចេកទេសនៃការស្ថាបនាផ្លូវថ្នល់
- ចាត់វិធានការក្នុងការបង្ក្រាប និងទប់ស្កាត់បទល្មើសដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ឱ្យបានទាន់ពេលវេលា ។

**មាត្រា ៣ .-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះសកម្មភាពដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងការថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## រចនាសម្ព័ន្ធ និងសមាសភាព

**មាត្រា ៤ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់មានរចនាសម្ព័ន្ធ ដូចតទៅ÷

១- គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។
២- គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ។
៣- អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។
៤- លេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ។

**មាត្រា ៥ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានសមាសភាព ដូចខាងក្រោម :

| | |
|---|---|
| ១- រដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៣- រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤- អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៥- មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៦- អភិបាលរាជធានី អភិបាលខេត្ត | សមាជិក |
| ៧- ប្រធាន គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ | សមាជិកអចិន្ត្រៃយ៍ |

ប្រធានគណៈកម្មាធិការ ដឹកនាំការត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ អាចអញ្ជើញ

តំណាងក្រសួង ស្ថាប័ន និងអភិបាលរាជធានី អភិបាលខេត្តពាក់ព័ន្ធ ចូលរួមប្រជុំតាមការចាំបាច់ ។ គណៈកម្មាធិការនេះមានសិទ្ធិប្រើប្រាស់ត្រាររបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៦ ---**

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ត្រូវតែងតាំងដោយសេចក្តីសម្រេច របស់ប្រធានគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ។ សមាជិកគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍អាចមានការផ្លាស់ប្តូរតាមការចាំបាច់ ។

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- តំណាងរដ្ឋមន្ត្រី ក្រសួងសាធារណការ និងដឹកជញ្ជូន | ប្រធាន |
| ២- តំណាង អគ្គនាយកដ្ឋានសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| ៣- តំណាង អគ្គស្នងការនគរបាលជាតិ | សមាជិក |
| ៤- តំណាង មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស | សមាជិក |
| ៥- តំណាង អាជ្ញាធរដែនដីរាជធានី ខេត្ត | សមាជិក |
| ៦- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៧- តំណាង អគ្គនាយកដ្ឋានដឹកជញ្ជូននៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៨- ប្រធាន មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត | សមាជិក |

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានទីតាំងនៅទីស្តីការក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ៧ ---**

អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានសមាសភាពដូចខាងក្រោម :

| | |
|---|---|
| ១- តំណាង មន្ទីរសាធារណការ និងដឹកជញ្ជូនរាជធានី ខេត្ត | មានឋានៈស្មើនឹងអនុប្រធានមន្ទីរ |
| ២- តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន | មានឋានៈស្មើនឹងអនុប្រធានការិយាល័យ |
| ៣- តំណាង សាលារាជធានី ខេត្ត | មានឋានៈស្មើនឹងប្រធានការិយាល័យខេត្ត |
| ៤- តំណាង ស្នងការនគរបាលរាជធានី ខេត្ត | មានឋានៈស្មើនឹងប្រធានការិយាល័យខេត្ត |
| ៥- តំណាង មេបញ្ជាការកងរាជអាវុធហត្ថរាជធានី ខេត្ត | មានឋានៈស្មើនឹងប្រធានការិយាល័យខេត្ត |

៦- ក្នុងករណីចាំបាច់ អាចស្នើសុំមន្ត្រីជំនាញមួយចំនួនតាមតំណាងខាងលើ ដើម្បីជាជំនួយការ ។

ការតែងតាំងសមាសភាពអង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកលើសទម្ងន់កម្រិតកំណត់ តាមការស្នើសុំរបស់ប្រធានគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ។

**មាត្រា ៨ ---**

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដែលមានសមាសភាពដូចខាងក្រោម :

១- ប្រធាន ដែលមានឋានៈស្មើអនុប្រធាននាយកដ្ឋាន ។

២- អនុប្រធាន ដែលមានឋានៈស្មើប្រធានការិយាល័យ ។

៣- សមាជិកមួយចំនួន តាមតម្រូវការចាំបាច់ ។

## ជំពូកទី ៣
## តួនាទី និងភារកិច្ច

**មាត្រា ៩ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់មានភារកិច្ច ដូចតទៅ ÷

- រៀបចំ និងដាក់ចេញវិធានការទប់ស្កាត់រាល់សកម្មភាពដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំ និងដាក់ចេញនូវគោលការណ៍អនុវត្តការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នៅលើបណ្តាញផ្លូវជាតិ នៃព្រះរាជាណាចក្រកម្ពុជា
- សម្របសម្រួល តាមដាននិងត្រួតពិនិត្យការអនុវត្តន៍ការងាររបស់គណៈកម្មាធិការសម្របសម្រួល អចិន្ត្រៃយ៍
- រាយការណ៍ជូនរាជរដ្ឋាភិបាល អំពីសកម្មភាពត្រួតពិនិត្យយានយន្ត ដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- អនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រាជរដ្ឋាភិបាល ។

**មាត្រា ១០ .-**

គណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ មានភារកិច្ចដូចតទៅ ÷

- រៀបចំសេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុត្តនានា របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំសមាសភាពរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំកំណត់ទីតាំងរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- រៀបចំគម្រោងថវិកាប្រចាំឆ្នាំ របស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដើម្បីដាក់ក្នុងកញ្ចប់ថវិកាក្រសួងសាធារណការ និងដឹកជញ្ជូន
- សម្របសម្រួលនិងជំរុញសកម្មភាពត្រួតពិនិត្យ របស់អង្គភាពត្រួតពិនិត្យ និងស្ថានីយថ្លឹងទម្ងន់យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- កំណត់កម្មវិធីការងាររបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- បែងចែកតួនាទី និងភារកិច្ចរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ទំនាក់ទំនង និងសហការជាមួយស្ថាប័នមានសមត្ថកិច្ច និងអាជ្ញាធរដែនដីពាក់ព័ន្ធ
- ណែនាំការផាកពិន័យតាមកំហុសជាក់ស្តែងដោយអនុលោមតាមមាត្រា ៨៤ នៃច្បាប់ចរាចរណ៍ផ្លូវគោក និងបទប្បញ្ញត្តិផ្សេងៗទៀតជាធរមាន
- អាចប្រើប្រាស់មន្ត្រីជំនាញ តាមសមត្ថភាពរៀងៗខ្លួន តាមពេលវេលានិងទំហំការងារចាំបាច់
- បង្កើតក្រុមត្រួតពិនិត្យចល័តពិសេសសំរាប់បេសកកម្មមួយរយៈ ដើម្បីធ្វើការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ នៅតាមបណ្តាញផ្លូវ ដែលពុំមានស្ថានីយថ្លឹងយានយន្ត
- គ្រប់គ្រងប្រាក់ដែលបានមកពីការផាកពិន័យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់
- ត្រូវកំណត់បទបញ្ជាផ្ទៃក្នុងសម្រាប់អនុវត្តការងារ ឱ្យមានប្រសិទ្ធភាព
- អនុវត្តភារកិច្ចផ្សេងទៀត ដែលគណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូន ប្រគល់ជូន ។

**មាត្រា ១១ .-**

តួនាទី និងភារកិច្ចរបស់អង្គភាពស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងលេខាធិការដ្ឋាននៃគណៈកម្មាធិការសម្របសម្រួលអចិន្ត្រៃយ៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៤
## ស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ និងឯកសណ្ឋាន

**មាត្រា ១២ .-**

ស្ថានីយថ្លឹងយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ ដែលបានបង្កើតឡើងនៅតាមបណ្តាញផ្លូវជាតិត្រូវមានឈ្មោះ ទីតាំងជាក់លាក់ និងមានមន្ត្រីបម្រើការងារក្នុងស្ថានីយនីមួយៗឱ្យបានសមស្របតាមការកំណត់ ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះ ។

ចំនួនស្ថានីយថ្លឹងយានយន្ត ឈ្មោះស្ថានីយ និងទីតាំងស្ថានីយ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

**មាត្រា ១៣ .-**

ក្នុងពេលប្រតិបត្តិការងារនៅតាមស្ថានីយថ្លឹងទម្ងន់ និងធ្វើសកម្មភាពចល័តត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មន្ត្រីត្រួតពិនិត្យដែលត្រូវបានចាត់តាំងឱ្យបំពេញការងារ ត្រូវស្លៀកពាក់ឯកសណ្ឋាន និង មានប័ណ្ណសម្គាល់ខ្លួន ។ ចំពោះមន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថត្រូវស្លៀកពាក់ឯកសណ្ឋានរបស់ខ្លួន ។ ឯកសណ្ឋាន និងប័ណ្ណសម្គាល់ខ្លួនរបស់មន្ត្រីស្ថានីយថ្លឹងយានយន្តដឹកជញ្ជូន លើសទម្ងន់កម្រិតកំណត់នៅតាមស្ថានីយថ្លឹងនីមួយៗ និងមន្ត្រីក្រុមត្រួតពិនិត្យចល័តពិសេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ។

## ជំពូកទី ៥
## អំពីថវិកា

**មាត្រា ១៤ .-**

គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ មានខ្ទង់ថវិកាដោយឡែកដែលជាឧបសម្ព័ន្ធនៃកញ្ចប់ថវិការបស់ក្រសួងសាធារណការ និងដឹកជញ្ជូន ។

ប្រភពធនធាន និងថវិការបស់គណៈកម្មាធិការដឹកនាំការត្រួតពិនិត្យ យានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់ រួមមាន ÷

- ថវិកាជាតិ ។
- ហិរញ្ញប្បទានសហប្រតិបត្តិការ ពីក្នុង និងក្រៅប្រទេស ដែលផ្តល់ដោយអង្គការអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ។

**មាត្រា ១៥ .-**

ប្រាក់ដែលទទួលបានពីការផាកពិន័យ ត្រូវបង់ចូលថវិការដ្ឋចំនួន៦០% និងប្រាក់៤០% ត្រូវបានអនុញ្ញាតជាវង្វាន់

ដល់ភ្នាក់ងារមានសមត្ថកិច្ច ដែលបានខិតខំអនុវត្តភារកិច្ចរបស់ខ្លួន ។

## ជំពូកទី ៦
## អវសានប្បញ្ញត្តិ

**មាត្រា ១៦ .-**

អនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣ ស្តីពីការបង្កើតគណៈកម្មការត្រួតពិនិត្យយានយន្តដឹកជញ្ជូនលើសទម្ងន់កម្រិតកំណត់អតិបរមា និងបទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៧ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី អភិបាលខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៥

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីសូមចុះហត្ថលេខា
**រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន**

**ត្រាំ អ៊ីវតឹក**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
- ដូចមាត្រា ១៧
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ